**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៤៧០ **អយក.ឋក**

ថ្ងៃអង្គារ ៨រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥

**ជម្រាបជូន**

**- ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពថវិកាថ្នាក់កណ្តាល**
**- លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

កម្មវត្ថុ៖ សំណើសុំពន្លឿនការទូទាត់ថវិកាកម្មវិធីពេញលេញរបស់អង្គភាពក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការអនុវត្តថវិកាក្នុងឆ្នាំ២០២៥។

**យោង៖** សារាចរណែនាំលេខ ០១៣ សហវ.ស.រ.អថ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធាន ជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញចាប់តាំងពីឆ្នាំ២០១៥ មកម្ល៉េះ ហើយបច្ចុប្បន្នមានអង្គភាពថវិកាចំនួន៥៩ (រដ្ឋបាលកណ្តាលចំនួន៣៤ និងមន្ទីរអយក រាជធានី ខេត្តចំនួន ២៥) និងកម្មវិធីចំនួន៥ ព្រមទាំងបានវិមជ្ឈការការគ្រប់គ្រងហិរញ្ញវត្ថុជូនអង្គភាពថវិកាក្នុងគោលបំណងផ្តល់ប្រតិភូកម្មសិទ្ធិអំណាចជូនអង្គភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ឱ្យប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព សម្រាប់ការអនុវត្តថវិកាតាមរយៈការប្រគល់អាណត្តិកិច្ចច្បាស់លាស់។ ទន្ទឹមនឹងនេះ ក្រសួងបានពង្រឹងសមត្ថភាពបន្ថែម ជូនថ្នាក់ដឹកនាំនិងមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុឱ្យយល់ដឹងកាន់តែស៊ីជម្រៅស្តីពីការរៀបចំថវិកា ការអនុវត្តថវិកា និងការពិនិត្យតាមដាននិងវាយតម្លៃ ព្រមទាំងបានបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា (EFMS) ជូនដល់អង្គភាពប្រើប្រាស់។

ក្រសួងបានពិនិត្យឃើញថា គិតត្រឹមថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២៥ ការអនុវត្តថវិការបស់ក្រសួងសរុប ចំនួន ៦៧,០៣% បើធៀបនឹងឥណទានកែតម្រូវ ក្នុងនោះរដ្ឋបាលកណ្តាលចំនួន ៥៣,៣៣% និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តចំនួន៧៥,៥៧% ទាបជាងឆ្នាំ២០២៤ ចំនួន ២,៥២% ដែលជាបច្ច័យមួយធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ផែនការសកម្មភាព និងសូចនាករគោលដៅរបស់ក្រសួង។ ក្នុងន័យនេះ ដើម្បីចូលរួមពង្រឹងនិងពន្លឿនការអនុវត្តថវិកាឆ្នាំ២០២៥ ឱ្យកាន់តែមានភាពប្រសើរនិងទាន់ពេលវេលា ហើយស្របជាមួយច្បាប់គតិយុត្ត ក្រសួងស្នើសុំកំណត់៖

**១**-ប្រធានកម្មវិធី ប្រធានអង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រោមឱវាទក្រសួង ត្រូវចូលរួមជំរុញនិងពន្លឿនរាល់ប្រតិបត្តិការនៃការអនុវត្តថវិកាឱ្យស្របតាមក្របខណ្ឌពេលវេលា និងផែនការសកម្មភាព ព្រមទាំងស្របតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន និងសារាចរណែនាំលេខ ០១៣ សហវ.សរ.អថ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥ ស្តីពីការបិទបញ្ជីចំណូល ចំណាយថវិកា និងការធ្វើរបាយការណ៍បូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាកំហិត។

**២**-មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ក្រោមឱវាទក្រសួង ត្រូវធ្វើការផ្ទៀងផ្ទាត់តួលេខអនុវត្តចំណូល ចំណាយថវិការបស់អង្គភាពជាមួយរតនាគាររាជធានី ខេត្ត និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយត្រូវរៀបចំរបាយការណ៍បូកសរុបអនុវត្តចំណូល ចំណាយថវិកា បញ្ជូនមកក្រសួង ត្រឹមថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦ ជាកំហិត។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

៣-ប្រធានកម្មវិធី ប្រធានអង្គភាពថវិកានៅថ្នាក់រដ្ឋបាលកណ្តាល ត្រូវពន្លឿនការបញ្ចូលអាណត្តិទូទាត់ក្នុងប្រព័ន្ធ EFMS មុនថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ ជាកំហិត ដើម្បីក្រសួងមានមូលដ្ឋានបូកសរុបផ្ទៀងផ្ទាត់តួលេខចំណូល ចំណាយថវិកា។

៤-ការបោះផ្សាយអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម និង/ឬប្រតិបត្តិការចំណាយ (Voucher) គ្រប់ប្រភេទចុងក្រោយបង្អស់ដែលបានចុះហត្ថលេខាអាណាប័កដើមខ្សែ ត្រូវបញ្ជូនមកនាយកដ្ឋានហិរញ្ញវត្ថុយ៉ាងយូរត្រឹមសប្តាហ៍ទី២ នៃខែធ្នូ ឆ្នាំ២០២៥ ដើម្បីអនុម័តក្នុងប្រព័ន្ធ FMIS រីឯអង្គភាពថវិកាដែលជាអាណាប័កផ្ទេរសិទ្ធិ ក៏ត្រូវបញ្ជូនយ៉ាងយូរត្រឹមដើមសប្តាហ៍ទី៣ នៃខែធ្នូ ឆ្នាំ២០២៥ ដល់មន្ត្រីត្រួតពិនិត្យថវិកាអមក្រសួងអប់រំ យុវជន និងកីឡា។ ដោយឡែកក្នុងករណីអង្គភាពថវិកាបោះផ្សាយអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម និង/ឬប្រតិបត្តិការចំណាយ (Voucher) មិនមានឯកសារគតិយុត្តភ្ជាប់មកជាមួយគ្រប់គ្រាន់ ត្រឹមត្រូវ និងច្បាស់លាស់ នោះក្រសួងនឹងមិនឯកភាពផ្តល់ជូនតាមសំណើ សម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៥-ក្នុងករណីការបោះផ្សាយអាណត្តិបើកប្រាក់ អាណត្តិនិយ័តកម្ម និង/ឬប្រតិបត្តិការចំណាយ (Voucher) ចុងក្រោយបង្អស់របស់អង្គភាពថវិកាមិនទាន់ពេលដូចនឹងចំណុចទី២ ខាងលើ ក្រសួងនឹងមិនអនុញ្ញាតឱ្យដំណើរការក្នុងប្រព័ន្ធ FMIS ដោយតម្រូវឱ្យប្រើប្រាស់ឥណទានថវិកានៅឆ្នាំបន្ទាប់គឺឆ្នាំ២០២៦ ដើម្បីទូទាត់ការចំណាយនេះសម្រាប់អង្គភាពនៅថ្នាក់រដ្ឋបាលកណ្តាល។

៦-គ្រប់ប្រធានអង្គភាព ត្រូវចូលរួមជំរុញការប្រើប្រាស់ប្រព័ន្ធ EFMS តាមស្មារតីនៃលិខិតលេខ ៤៣១០ អយក.ហវ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ លើមុខងារមានជាអាទិ៍៖ វិភាជថវិកា (BA) បញ្ជាទិញ (PO) គណនីត្រូវសង (AP) និងរបាយការណ៍ ដើម្បីពង្រឹងការកត់ត្រាទិន្នន័យ ឱ្យស្របតាមការអនុវត្តសកម្មភាពជាក់ស្តែងរបស់អង្គភាពសាមី ព្រមទាំងបង្កលក្ខណៈងាយស្រួលក្នុងការផ្លាស់ប្តូរទិន្នន័យជាមួយប្រព័ន្ធ FMIS របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាបច្ច័យយ៉ាងល្អសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុឱ្យប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាពខ្ពស់។

៧-គ្រប់ប្រធានអង្គភាព ត្រូវប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវភាពជាម្ចាស់ក្នុងការពិនិត្យតាមដាន និងចូលរួមយ៉ាងសកម្មនូវការអនុវត្តថវិកាឱ្យទាន់ពេលវេលា និងត្រឹមត្រូវ ដើម្បីធានាស្ថិរភាព និងចីរភាពនៃតុល្យភាពចំណាយ ក៏ដូចជាលើកកម្ពស់សុខុមាលភាពការងាររបស់អង្គភាពសាមី។

៨-នាយកដ្ឋានហិរញ្ញវត្ថុត្រូវទទួលបន្ទុកជាអ្នកសម្របសម្រួលជាមួយអង្គភាពក្រោមឱវាទក្រសួង ក្នុងករណីមានបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តថវិកា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន** មេត្តាជ្រាប និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា តាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- អគ្គលេខាធិការដ្ឋាន
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ